ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សេចក្តីថ្លែងការណ៍

## អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

3

- **អ្នកនាំពាក្យក្រសួងការពារជាតិ ព្រះរាជាណាចក្រកម្ពុជា** សូមធ្វើការបំភ្លឺលើព័ត៌មានបំភ្លើស ដែលចុះផ្សាយក្នុងគេហទំព័រ ក្រុងថេបធុរកិច្ច នៅវេលាម៉ោង ២១:៥៧នាទី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលថា ក្រុមការងាររួមបង្កើតឡើងដោយគណៈកម្មាធិការព្រំដែនទូទៅ (GBC) " នឹងមានការពិចារណា រឿងការ ដក់សហគមន៍កម្ពុជា ចេញពីវត្តកែវសិក្ខាគីរីស្វារៈ " ។

ដោយឡែកប្រភពសារព័ត៌មានបាងកកប៉ុស្ដិ៍ ដែលផ្សាយវេលាម៉ោង ១២:០០នាទី ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ បាននិយាយថា " លោកឧត្តមសេនីយ៍ **យុទ្ធស័ក្ត សាស៊ីប្រាផា** រដ្ឋមន្ត្រីក្រសួងការពារជាតិ រាជាណាចក្រថៃឡង់ដ៏ បាននិយាយថា ក្រុមការងាររួម Joint Working Group (JWG ) អាចនឹងជួបប្រជុំគ្នានៅទីក្រុងបាងកកនាខែក្រោយ ដើម្បីពិភាក្សាពិស្តារ ពីការដកកងទ័ព ការដាក់ពង្រាយអ្នកសង្កេតការណ៍ ការរៀបចំទីតាំងផ្សារកម្ពុជានៅកន្លែងថ្មី និងតាំងទីលំនៅថ្មីឲ្យសហគមន៍កម្ពុជាចេញពីវត្តកែវសិក្ខាគីរីស្វារៈ " ។

- **អ្នកនាំពាក្យក្រសួងការពារជាតិ ព្រះរាជាណាចក្រកម្ពុជា** សូមបញ្ជាក់ថា កិច្ចប្រជុំរបស់គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ (GBC) លើកទី៨ ដែលបានប្រព្រឹត្តទៅ នៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១នោះ ភាគីទាំងពីរ បានឯកភាព:

-អនុវត្តសាលដីកាបង្គាប់របស់តុលាការអន្តរជាតិ (ICJ) ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ស្តីពីវិធានការបណ្តោះអាសន្ន ឲ្យមានតម្លាភាព ស្មើភាព និងមានភាពទៀតទាត់។

-សម្រេចបង្កើតក្រុមការរួម Joint Working Group (JWG) ដែលក្រុមការងាររួមនេះ នឹងធ្វើការពិភាក្សាតែលើបញ្ហាទាក់ទង ទៅនឹងការអនុវត្តន៍សាលដីកាបង្គាប់ របស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) នៅក្នុងតំបន់គ្មានកងទ័ពបណ្តោះអាសន្ន (PDZ) ព្រមទាំងធ្វើការកែសម្រួលបុគ្គលិកយោធាចេញពីតំបន់គ្មានយោធាបណ្តោះអាសន្ន (PDZ) ឲ្យបានឆាប់បំផុត ស្របពេលជាមួយគ្នា ប្រកបដោយតម្លាភាពស្ថិតក្រោមការត្រួតពិនិត្យ ក្រុមអ្នកសង្កេតការណ៍កម្ពុជា ថៃ ឥណ្ឌូនេស៊ីតែប៉ុណ្ណោះ។

- **អ្នកនាំពាក្យក្រសួងការពារជាតិ ព្រះរាជាណាចក្រកម្ពុជា** សូមគាំទ្រយ៉ាងពេញទំហឹង ចំពោះលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ (GBC) លើកទី៨ ហើយសូមច្រានចោលនូវព័ត៌មានទាំងឡាយណាដែលផ្ទុយពីសេចក្តីថ្លែងការណ៍រួម នៃកិច្ចប្រជុំខាងលើ។

*រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១*

ទីស្តីការក្រសួងការពារជាតិ ទូរស័ព្ទ-ទូរសារ : (៨៥៥) ០២៣ ៨៨៣២៧៤ E.Mail : Minadef@camnet.com.kh